# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅ នៃអនុគណៈកម្មាធិការចំណុះគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីសមាសភាព តួនាទី ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តិទៅនៃអនុគណៈកម្មាធិការ ចំណុះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប )។

## ជំពូកទី២

## អនុគណៈកម្មាធិការនៃ គ.ជ.អ.ប

**មាត្រា ២.-**

គ.ជ.អ.ប ត្រូវមានអនុគណៈកម្មាធិការជាជំនួយការ ដូចខាងក្រោម ÷

- អនុគណៈកម្មាធិការមុខងារ និងធនធាន
- អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

ក្រៅពីអនុគណៈកម្មាធិការខាងលើនេះ គ.ជ.អ.ប អាចស្នើសុំបង្កើតអនុគណៈកម្មាធិការបន្ថែមទៀត តាមការចាំបាច់។

**មាត្រា ៣.-**

អនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប មានសមាសភាពដូចខាងក្រោម ÷

**ក-<u>អនុគណៈកម្មាធិការមុខងារ និងធនធាន</u>**

| | |
|---|---|
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

**ខ-<u>អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ</u>**

| | |
|---|---|
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

គ-<u>អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ</u>

| | |
|---|---|
| - រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

ឃ-<u>អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ</u>

| | |
|---|---|
| - រដ្ឋលេខាធិការ នៃក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

## មាត្រា ៤.-

រដ្ឋលេខាធិការដែលទទួលជាប្រធានអនុគណៈកម្មាធិការ អនុប្រធានអនុគណៈកម្មាធិការ និងរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការដែលទទួលជាសមាជិកអនុគណៈកម្មាធិការ ត្រូវចាត់តាំងដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃក្រសួង ស្ថាប័ននោះ ហើយដែលទទួលស្គាល់ដោយ គ.ជ.អ.ប ។

## មាត្រា ៥.-

សមាគមក្រុមប្រឹក្សាតាមប្រភេទនីមួយៗដែលបានបង្កើត និងចុះបញ្ជីស្របតាមនីតិវិធីកំណត់ ត្រូវជ្រើសរើសតំណាងម្នាក់ៗ ដើម្បីធ្វើជាសមាជិកអនុគណៈកម្មាធិការនីមួយៗ ។

ករណីក្រុមប្រឹក្សាប្រភេទណាមួយ មិនទាន់បានបង្កើតសមាគមតាមនីតិវិធីដែលកំណត់ សមាជិកភាពនៃតំណាងនោះក្នុងអនុគណៈកម្មាធិការត្រូវរក្សាទុកឱ្យនៅទំនេររហូតដល់ក្រុមប្រឹក្សាប្រភេទនោះបង្កើតបានសមាគម ។

## មាត្រា ៦.-

អនុគណៈកម្មាធិការនីមួយៗ អាចអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍អន្តរជាតិ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ឱ្យចូលសង្កេតការណ៍ក្នុងកិច្ចប្រជុំរបស់ខ្លួន ឬអាចធ្វើការពិគ្រោះពិភាក្សា ដើម្បីប្រមូលអនុសាសន៍ពីតំណាង ឬ អ្នកពាក់ព័ន្ធទាំងនោះតាមការចាំបាច់ ។

## មាត្រា ៧.-

អនុគណៈកម្មាធិការនីមួយៗត្រូវបង្កើតក្រុមការងារ ដើម្បីជួយសិក្សាអំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងការងារកិច្ចរបស់ខ្លួន ។
ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងាររបស់អនុគណៈកម្មាធិការត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប ។

**មាត្រា ៨.-**

ក្រសួង ស្ថាប័ននីមួយៗនៃ គ.ជ.អ.ប ត្រូវបង្កើតឱ្យមានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ ប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ។

ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័ននីមួយៗ ត្រូវស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់រដ្ឋមន្ត្រី ឬប្រធាន ស្ថាប័ននៃក្រសួង ស្ថាប័ននោះ ។

ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័ននីមួយៗ មានភារកិច្ចរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលពាក់ព័ន្ធមុខងារ និងការទទួលខុសត្រូវនៃក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីអនុវត្ត ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការសកម្មភាព ព្រមទាំងសេចក្តីសម្រេចរបស់គ.ជ.អ.ប ហើយត្រូវចូលរួមគាំទ្រដល់សកម្មភាពអនុគណៈកម្មាធិការ និងសកម្មភាពរបស់ គ.ជ.អ.ប ។

គ.ជ.អ.ប អាចធ្វើការណែនាំអំពីទំនាក់ទំនងការងារ កិច្ចសហការ និងការគាំទ្រពីក្រុមការងារវិមជ្ឈការ និង វិសហមជ្ឈការ ប្រចាំក្រសួង ស្ថាប័នជាមួយយន្តការនានារបស់ខ្លួន ។

## ជំពូកទី៣

## ភារកិច្ចជាក់ស្តែងរបស់អនុគណៈកម្មាធិការ

**មាត្រា ៩.-**

អនុគណៈកម្មាធិការមុខងារ និងធនធានមានភារកិច្ចជួយ និងផ្តល់យោបល់ ព្រមទាំងអនុសាសន៍ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងដល់ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប ក្នុងការកំណត់ និងការផ្ទេរមុខងារ និងធនធានឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១០.-**

អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ មានភារកិច្ចជួយ និងផ្តល់យោបល់ ព្រមទាំងអនុសាសន៍នានាដល់ គ.ជ.អ.ប លើការងារទាំងអស់ ដែលទាក់ទងដល់ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប អំពីកិច្ចការសារពើពន្ធ ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១១.-**

អនុគណៈកម្មាធិការបុគ្គលិករបស់ថ្នាក់ក្រោមជាតិ មានភារកិច្ចជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងនឹងភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប ក្នុងការកំណត់ ការរៀបចំបុគ្គលិក ការរៀបចំឱ្យមានក្របខ័ណ្ឌបុគ្គលិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

មាត្រា ១២.-

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ មានភារកិច្ចជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងនឹងភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប អំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

មាត្រា ១៣.-

គ.ជ.អ.ប អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់អនុគណៈកម្មាធិការរបស់ខ្លួនតាមការចាំបាច់ ។

## ជំពូកទី៤

## តួនាទី និងរបៀបរបបការងាររបស់អនុគណៈកម្មាធិការ

មាត្រា ១៤.-

អនុគណៈកម្មាធិការ នៃគ.ជ.អ.ប មានតួនាទីធ្វើការសិក្សា លើកយោបល់ និងផ្តល់អនុសាសន៍រាល់កិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ សម្រេច ។

មាត្រា ១៥.-

ក្នុងការសិក្សា ពិគ្រោះពិភាក្សា ដើម្បីលើកយោបល់ និងផ្តល់អនុសាសន៍ជូន គ.ជ.អ.ប អនុគណៈកម្មាធិការនីមួយៗ ត្រូវពុះពារ ដើម្បីបង្កើត ជំរុញ និងទ្រទ្រង់ដល់និរន្តរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

មាត្រា ១៦.-

អនុគណៈកម្មាធិការនៃ គ.ជ.អ.ប ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់ ដោយផ្អែកតាម អត្ថន័យ គោលបំណង និងឆន្ទៈនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

មាត្រា ១៧.-

ដើម្បីផ្តល់យោបល់ និងអនុសាសន៍នានាដល់ គ.ជ.អ.ប អនុគណៈកម្មាធិការត្រូវធ្វើការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ។

មាត្រា ១៨.-

ក្នុងការអនុវត្តការងាររបស់ខ្លួន អនុគណៈកម្មាធិការនីមួយៗត្រូវផ្អែកតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការសកម្មភាព និងសេចក្តីសម្រេចនានារបស់ គ.ជ.អ.ប ។

**មាត្រា ១៩.-**

អនុគណៈកម្មាធិការត្រូវតាមដាន ត្រួតពិនិត្យ និងធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំជូន គ.ជ.អ.ប ឬរបាយការណ៍តាមពេលវេលាជាក់លាក់ណាមួយដែលកំណត់ដោយ គ.ជ.អ.ប ទាក់ទិននឹងកិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់អនុគណៈកម្មាធិការនីមួយៗ ។

សេចក្តីរាយការណ៍ និងអនុសាសន៍ខាងលើត្រូវបញ្ជូនមកលេខាធិការដ្ឋាន ដើម្បីសម្របសម្រួល និងបំពេញបែបបទដាក់ជូន គ.ជ.អ.ប ពិនិត្យ សម្រេចឱ្យបានសមស្រប និងទាន់ពេលវេលា។

**មាត្រា ២០.-**

គ.ជ.អ.ប អាចធ្វើប្រតិភូកម្មនូវកិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនជូនអនុគណៈកម្មាធិការ បន្ថែមពីលើភារកិច្ច និងសិទ្ធិអំណាចជាក់លាក់របស់អនុគណៈកម្មាធិការ ។

ក្នុងការធ្វើប្រតិភូកម្មខាងលើនេះ គ.ជ.អ.ប អាចប្រគល់ភារកិច្ចឱ្យអនុគណៈកម្មាធិការច្រើនជាងមួយ ដើម្បី សហការគ្នាសិក្សាលើកយោបល់ និងផ្តល់អនុសាសន៍តាមការចាំបាច់ ។

**មាត្រា ២១.-**

លេខាធិការដ្ឋាននៃ គ.ជ.អ.ប គឺជាលេខាធិការដ្ឋាននៃអនុគណៈកម្មាធិការ ។

**មាត្រា ២២.-**

អនុគណៈកម្មាធិការនីមួយៗត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានអនុគណៈកម្មាធិការ ហើយត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការ ។

អនុប្រធានអនុគណៈកម្មាធិការត្រូវជំនួសប្រធានក្នុងពេលប្រធានអនុគណៈកម្មាធិការអវត្តមាន ។

**មាត្រា ២៣.-**

កិច្ចប្រជុំអនុគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកអនុគណៈកម្មាធិការលើសពីពាក់កណ្តាលនៃសមាជិកអនុគណៈកម្មាធិការទាំងមូលបានចូលរួម ។

**មាត្រា ២៤.-**

ក្នុងការលើកយោបល់ ឬផ្តល់អនុសាសន៍នានាជូន គ.ជ.អ.ប អនុគណៈកម្មាធិការត្រូវខិតខំសម្របសម្រួលឱ្យមានការមូលមតិគ្នានៅក្នុងចំណោមសមាជិកអនុគណៈកម្មាធិការដែលមានវត្តមានក្នុងកិច្ចប្រជុំ។ ក្នុងករណីមិនមានការមូលមតិគ្នាបាន អនុគណៈកម្មាធិការត្រូវធ្វើការសម្រេចដោយសម្លេងភាគច្រើននៃសមាជិកអនុគណៈកម្មាធិការទាំងមូល ។

**មាត្រា ២៥.-**

លេខាធិការដ្ឋានត្រូវចាត់មន្ត្រីក្នុងលេខាធិការដ្ឋានឱ្យចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់អនុគណៈកម្មាធិការ ។

អនុគណៈកម្មាធិការ អាចអនុញ្ញាតឱ្យមន្ត្រី ឬអ្នកពាក់ព័ន្ធនានាចូលរួមប្រជុំអនុគណៈកម្មាធិការតាមការចាំបាច់។ មន្ត្រីដែលចូលរួមប្រជុំខាងលើនេះ មានសិទ្ធិផ្តល់យោបល់ដល់អនុគណៈកម្មាធិការ ប៉ុន្តែគ្មានសិទ្ធិអនុម័តលើការសម្រេចណាមួយរបស់អនុគណៈកម្មាធិការបានឡើយ ។

**មាត្រា ២៦.-**

រាល់កិច្ចប្រជុំទាំងអស់របស់អនុគណៈកម្មាធិការ ត្រូវមានកំណត់ហេតុប្រជុំដែលរៀបចំដោយក្រុមការងារ នៃអនុគណៈកម្មាធិការ ។

កំណត់ហេតុប្រជុំនៃអង្គប្រជុំនីមួយៗ ត្រូវផ្តល់ជូនលេខាធិការដ្ឋានយ៉ាងយូរប្រាំ (០៥) ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ ។ លេខាធិការដ្ឋានត្រូវធ្វើការឃ្លូកសរុបលទ្ធផលនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានា ដើម្បីរាយការណ៍សុំការសម្រេចពី គ.ជ.អ.ប ។

**មាត្រា ២៧.-**

គ.ជ.អ.ប អាចកំណត់បន្ថែមទៀតអំពីរបៀបរបបការងាររបស់អនុគណៈកម្មាធិការនានាតាមការចាំបាច់ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៩.-**

ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងសមាសភាពដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ២៩
- ឯកសារ កាលប្បវត្តិ